**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

MINISTRY OF ECONOMY AND FINANCE

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ........សហវ. [illegible]

រាជធានីភ្នំពេញ,ថ្ងៃទី ១៦ ខែ សីហា ឆ្នាំ២០១៦

**គោរពជូន**

**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ**

**កម្មវត្ថុ:** ករណីសំណើសុំអនុម័តការចរចាថ្លៃ និងប្រគល់កិច្ចសន្យា ជូនមន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ធំ ស្តីពីការងារជួសជុលខួបដោយក្រាលក្រួសក្រហមផ្លូវចំនួន ០១ ខ្សែ ប្រវែង ១៦ ០៧០ម ទទឹងខ្នងលើ ៤,៥ម និង០៦ម កម្រាស់ ០,២ម ស្ថិតនៅក្នុងខេត្តកំពង់ធំ។

**យោង:** - លិខិតលេខ ១៨៩២ សហវ.អថ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៦ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- កំណត់ហេតុចរចាថ្លៃ នៅថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៦ របស់ គ.ល ក្រសួងអភិវឌ្ឍន៍ជនបទ
- លិខិតលេខ ០៩៣២/១៦ ក.អ.ជ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ របស់ក្រសួងអភិវឌ្ឍន៍ជនបទ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមជម្រាបជូនឯកឧត្តមរដ្ឋមន្ត្រីមេត្តាជ្រាបថា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ យល់ព្រមតាមសំណើរបស់ក្រសួងអភិវឌ្ឍន៍ជនបទ ក្នុងការប្រគល់កិច្ចសន្យា ជូនមន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ធំ ដើម្បីធ្វើការងារជួសជុលខួបដោយក្រាលក្រួសក្រហមផ្លូវចំនួន ០១ ខ្សែ (ផ្លូវសាលាវិស័យ-ចំណារថ្មី)ប្រវែង ១៦ ០៧០ម ទទឹងខ្នងលើ ៤,៥ម និង០៦ម កម្រាស់ ០,២ម ស្ថិតនៅក្នុងឃុំសាលាវិស័យ ឃុំសំបូរ ស្រុកប្រាសាទបល្ល័ង្គ និងប្រាសាទសំបូរ ខេត្តកំពង់ធំ ក្នុងតម្លៃសរុបចំនួន ១ ១៦៥ ៥០០ ០០០រៀល (មួយប៊ីលាន មួយរយហុកសិបប្រាំលាន ប្រាំរយពាន់រៀលគត់) ជាតម្លៃកិច្ចសន្យា។

ការជួលបន្តទៅឱ្យក្រុមហ៊ុនឯកជនត្រូវបានហាមឃាត់ជាដាច់ខាត។ បើអង្គភាពរដ្ឋណាមួយគ្មានលទ្ធភាពធ្វើខ្លួនឯងបានត្រូវដកហូតប្រគល់ឱ្យអង្គភាពរដ្ឋមួយទៀតជាអ្នកអនុវត្តវិញ។ ក្នុងករណីប្រគល់ឱ្យអង្គភាពរដ្ឋមួយទៀតជាអ្នកអនុវត្តត្រូវស្នើសុំការយល់ព្រមពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាមុនសិន។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមរដ្ឋមន្ត្រីមេត្តាជ្រាប និងមានវិធានការអនុវត្តបន្តឱ្យបានសមស្របតាមនីតិវិធីលទ្ធកម្មសាធារណៈតាមការគួរ ។

សូមឯកឧត្តមរដ្ឋមន្ត្រីទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ

**ជ. ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**រដ្ឋលេខាធិការ**

**ជូ ទិជិត្ត**

**ចម្លងជូន:**

- ខុទ្ទកាល័យ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- អគ្គនាយកដ្ឋានថវិកា
- សាលាខេត្តកំពង់ធំ
- មន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ធំ
- មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តកំពង់ធំ
- ឯកសារ-កាលប្បវត្តិ